# ប្រជុំកោះតាង A1



**ខេត្ត** : ក្រុងព្រះសីហនុ

**ស្រុក** : មិត្តភាព

**ផ្ទៃដី ( ហិកតា)** : ៦៦៧

**រយៈកំពស់ ( ម៉ែត្រ)** : ០ ដល់ ១៣៤

**កូអរដោនេចំណុចកណ្តាល** : ១០$^{0}$ ១៨΄ ជ ១០៣$^{0}$ ០៨΄ ក

**ការពិពណ៌នាទីកន្លែង**

តំបន់ IBA នេះ រួមមានប្រជុំកោះតាងដែលជាកោះតូចៗស្ថិតនៅក្នុងឈូងសមុទ្រនៃប្រទេសថៃ ដែលមានចំងាយប្រហែង ៥០គីឡូម៉ែត្រនៅប៉ែកនិរតីនៃក្រុងព្រះសីហនុ ។ កោះទាំងនោះស្ថិតនៅក្នុងសមុទ្រដែលមានទឹករាក់ៗ (រហូតដល់ប្រហែល៥០ ម៉ែត្រ) ហើយមានលក្ខណៈជាឆ្នេរខ្សាច់ ថ្ម និង ផ្ទាំងថ្មថ្ម ។ កោះទាំងនោះគ្របដណ្តប់ដោយព្រៃស្រោងរិចរិល និង ទ្រទ្រង់ប្រភេទព្រាបកោះដែលជាប្រភេទមានវត្តមាននៅតែតាមកោះក្នុងសមុទ្រ ។ លើសពីនេះទៀត គេបានកត់ត្រាប្រភេទត្រចៀកកាំកោះពីតំបន់ IBAនេះ ហើយពួកវាមករស់នៅលើកោះតូចៗទាំងឡាយដែលស្ថិតនៅជុំវិញកោះតាង ។

**ប្រភេទសត្វស្លាបសំខាន់ៗ**

| **ឈ្មោះខ្មែរ** | **ឈ្មោះអង់គ្លេស** | **ឈ្មោះវិទ្យាសាស្ត្រ** | **លក្ខណៈវិនិច្ឆ័យIBA** |
|---|---|---|---|
| ត្រចៀកកាំកោះ | Christmas island Frigatebird | *Fregata andrewsi* | A1 |
| ព្រាបកោះ | Nicobar Pigeon | *Caloenas nicobarica* | A1 |

**ប្រភេទអណ្តើក កន្ធាយ និង ក្រពើទទួលរងការគំរាមកំហែងពិភពលោក**

អណ្តើកស្និចបៃតង ។

**ការគំរាមកំហែងលើជីវៈចំរុះ**

ទោះជាតំបន់នេះមិនមានមនុស្សរស់នៅ ក្រៅពីបន្ទាយទាហានតូចមួយក៏ដោយ ក៏ការគំរាមកំហែងចំបងៗបានកើតមានឡើងនៅក្នុងតំបន់ដោយសារការរំខានពីសកម្មភាពមនុស្ស ជាពិសេស សកម្មភាពនេសាទត្រី ការប្រមាញ់ និង ការប្រមូលយកយកពងកូនប្រព្រឹត្តដោយមន្ត្រីយោធា និង អ្នកនេសាទ ។ ការគំរាមកំហែងមានសក្តានុពលមួយទៀត គឺពពួកមំសាសីដូចជាត្រកួលឆ្មា និង ឆ្កែព្រៃធ្វើដំណើរទៅកាន់កោះទាំងនោះ ដែលអាចនាំឱ្យមានការគំរាមកំហែងធ្ងន់ធ្ងរដល់ប្រភេទព្រាបកោះ ។

**អនុសាសន៍**

ការពិភាក្សាគួរតែធ្វើឡើងជាមួយថ្នាក់ដឹកនាំកងកម្លាំងប្រដាប់អាវុធ ដើម្បីត្រួតពិនិត្យការបរបាញ់សត្វព្រៃ និង សកម្មភាពប្រមូលយកពងកូននៅលើកោះទាំងឡាយ ។

**ឯកសារយោង**

Davidson, P. (2001) A further twelve new species for Cambodia. *Cambodia Bird News* 7: 26-35
Goes, F. and Davidson, P. eds. (2001) Recent sightings. *Cambodia Bird News* 8: 44-51.